# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

សំណុំរឿងព្រហ្មទណ្ឌលេខ ៣១១
ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០២២
សំណុំរឿងជំនុំជម្រះលេខ ១៥១
ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌលេខ ៦៦ “ឈ”
ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០២៣

## សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០២៣ វេលាម៉ោង ០៩ និង ០០នាទីព្រឹក ដោយមានសមាសភាព÷

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣១១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ ៦១ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតភូ[redacted] ខេត្តតាកែវ និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តតាកែវ កាន់សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] ចំរើន (ស្លាប់) ម្តាយឈ្មោះ [redacted] យ៉ាន់ (ស្លាប់) ជានីតិជន ទោសពីមុន “គ្មាន”។

ពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចភូមិចុងថ្នល់ សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថុល ភេទស្រី អាយុ ៦៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិចុងថ្នល់ សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ០៩២ ដ.ស.ព ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ ៨៩ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តតាកែវ។

### <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង២២ និង ៣០ នាទីយប់ ស្ថិតនៅចំណុចភូមិចុងថ្នល់ សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ មានជនត្រូវចោទឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ ៦១ឆ្នាំ បានធ្វើសកម្មភាពវាយ និងចាប់បោចសក់ទៅលើជនរងគ្រោះឈ្មោះ [redacted] ស្រីលាប ភេទស្រី អាយុ ៥៥ឆ្នាំ បណ្តាលឱ្យរងរបួសដាច់រលាត់ជង្គង់ និងត្រិចដៃខាងស្តាំ ហើយក្រោយមកក៏បានបន្តដាល់ទៅលើជនរងគ្រោះឈ្មោះ



Scanned with CamScanner

[redacted] ថុល ភេទស្រី អាយុ ៦៦ឆ្នាំ ចំថ្ពាសខាងឆ្វេងចំនួន ០១ដែបណ្ដាលឱ្យសន្លប់នៅនឹងកន្លែងកើតហេតុតែម្ដង ក្រោយកើតហេតុជនរងគ្រោះក៏បានដាក់ពាក្យបណ្ដឹងចូលទៅសមត្ថកិច្ច បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានឆ្លើយថា កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល៧ និង៣០នាទី បងជីដូនមួយរបស់ខ្លួនឈ្មោះ [redacted] រដ្ឋា ភេទប្រុស និងឈ្មោះ [redacted] សារិន ភេទប្រុស បានមកលេងកន្លែងលក់គុយទាវរបស់ខ្លួនដែលនៅក្បែរតស់ស្ពានថុងថ្នល់ និងបាននាំគ្នាហូបស្រាបៀរ ពេលកំពុងតែនាំគ្នាហូប ស្រាប់តែមាននារីម្នាក់បានចូលមកហូបជាមួយពួកខ្លួន និងរៀបចំចាក់ធុងបាសដើម្បីច្រៀងលេងកម្សាន្ត។ រហូតដល់ម៉ោងប្រហែល ១០ និង០៥នាទីយប់ ប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] ស្វយ បានមកប្រាប់ខ្លួនថា "បងបិទធុងបាសទៅដល់ម៉ោងសម្រាកហើយ" ភ្លាមនោះស្រាប់តែម្នាក់ស្រីដែលបានចូលមកផឹកស្រាជាមួយពួកខ្លួននោះបានប្រាប់ថា "កុំអាលបិទអីពូ ខ្ញុំសុំបង្ហើយកន្ទុយបទចម្រៀងបន្តិចសិន" រួចខ្លួនក៏បន្តចាក់បាស់ធម្មតាទៅ។ បន្តិចក្រោយមក ស្រាប់តែបងស្រីរបស់ខ្លួនឈ្មោះ [redacted] ថុល បានមកស្រែកថា "បើកគ្មានខ្លាចអាណាគោរពអាណាទេ មន្ត្រីរាជការអីថោកទាបអញ្ចឹង" ហើយខ្លួនក៏មិនបានតបអ្វីទាំងអស់ដែរ តែម្នាក់ស្រីដែលបានមកផឹកជាមួយខ្លួន បាននិយាយតបថា "មីងអើយ! អ្នកជិតខាងគ្នាទេ អនុគ្រោះគ្នាខ្លះទៅ" ហើយស្រាប់តែបងស្រីឈ្មោះ [redacted] មាស បានតបវិញថា "ដែងចេះស្អី! ដែងគ្រាន់តែជាស្រីចម្រៀងប៉ុណ្ណោះ" រួចក៏ស្រាប់តែមានការប្រកែកគ្នាតែម្ដង។ លុះបានមួយសន្ទុះក្រោយមក ស្រាប់តែមានឈ្មោះ [redacted] ស្រីលាប បានមកដល់ដែរ និងបានជជែកគ្នានៅពេលនោះតែម្ដង។ ពេលនោះបងរបស់ខ្លួនឈ្មោះ [redacted] ថុល និងក្មួយឈ្មោះ [redacted] ស្រីលាប បានដើរសំដៅទៅរកវាយនារីម្នាក់ដែលបានច្រៀងជាមួយពួកខ្លួន។ ដោយឃើញមានសភាពការណ៍មិនស្រួល ខ្លួនក៏បានចូលទៅឃាត់បំបែកចេញពីគ្នា រួចប្រាប់ទៅឈ្មោះ [redacted] ថុល និងឈ្មោះ [redacted] ស្រីលាប ថា "បើផ្ទះនៅកន្លែងណា, ដីនៅកន្លែងណាឱ្យទៅឈរកន្លែងនោះវិញទៅក្រែងលតេវាយ" ស្រាប់តែឈ្មោះ [redacted] ថុល និងឈ្មោះ [redacted] ស្រីលាប មិនព្រមចេញទៅនោះទេ ហើយថែមទាំងបានស្ទុះចូលមកបម្រុងនឹងវាយនារីម្នាក់នោះបន្ថែមទៀត រួចខ្លួនក៏បានចូលទៅឃាត់ម្ដងទៀត ទើបបណ្ដាលឱ្យមានការប្រតាយប្រតប់គ្នារួចឈ្មោះ [redacted] ស្រីលាប បានមកខ្វាចមុខខ្លួនបណ្ដាលឱ្យរយះមុខ កញ្ចឹងករហែកអាវ និងធ្វើឱ្យដាច់ខ្សែករបស់ខ្លួនដាច់មួយកំណាត់ថែមទៀតផង។ បន្ទាប់មកក៏មានឈ្មោះ ម៉ៅ ដែលត្រូវជាចៅរបស់ខ្លួន និងត្រូវជាកូនរបស់ឈ្មោះ [redacted] ស្រីលាប បានហក់មកដាល់១ដៃចំថ្ពាស់របស់ខ្លួនបណ្ដាលឱ្យពក រួចឈ្មោះ [redacted] ស្រីលាប បានយកស្បែកជើងរបស់គេគប់មកលើខ្លួន ត្រូវចំក្បាលខ្លួនពីខាងមុខមួយស្បែកជើងបន្ថែមទៀត។ ក្រោយមកក៏មានឈ្មោះ [redacted] ផល្លា ដែលត្រូវជាកូនរបស់ឈ្មោះ [redacted] ថុល បានមកតាមក្រោយ និងបានទៅបោចសក់ប្រពន្ធរបស់ខ្លួនដែលឈរនៅជិតនោះបោកទៅនឹងដី រួចអូសតាមផ្លូវបានចម្ងាយប្រហែលជា០៥ម៉ែត្រ និងបានយកជើងមកជាន់ដើមទ្រូង និងក្បាល ប្រពន្ធរបស់ខ្លួន ស្រាប់តែមានអ្នកជិតខាងចូលមកជួយឃាត់តែម្ដង។ ខ្លួនសូមបញ្ជាក់ថានៅថ្ងៃកើតហេតុខ្លួនពុំបានស្ទុះទៅវាយឈ្មោះ [redacted] ថុល នោះទេ គឺខ្លួនគ្រាន់តែបានយកដៃរង និងវៀសឱ្យគេចេញតែប៉ុណ្ណោះ។ ចំពោះឈ្មោះ [redacted] ស្រីលាប ខ្លួនក៏មិនបានបោចសក់ និងអូសក្បាលរបស់គេកាត់ផ្លូវបណ្ដាលឱ្យរងរបួសជើង ដូចការចោទប្រកាន់នោះទេ គឺរបួសនោះកើតឡើងដោយសារការប្រវាយប្រតប់គ្នាទៅវិញទៅមកប៉ុណ្ណោះ ហើយខ្លួនក៏មិនបានដឹងថាប្រវាយប្រតប់គ្នាត្រូវចំណុចណាខ្លះនោះទេ ព្រោះខ្លួនធ្វើឡើងដើម្បីគ្រាន់តែការពារខ្លួនប៉ុណ្ណោះ។ មួយវិញទៀតខ្លួនមិនមានគោលបំណងបង្ករឿងជាមួយបងស្រីរបស់ខ្លួនឈ្មោះ មាស ថុល នោះទេ ព្រោះខ្លួនតែងតែគោរពគាត់ និងទុកគាត់ដូចជាម្ដាយបង្កើតរបស់ខ្លួនអញ្ចឹង ហើយនៅថ្ងៃកើតហេតុបងស្រីរបស់ខ្លួនជាអ្នកមករករឿង និងជេរបញ្ចោរកន្លែងលក់របស់ខ្លួនមុននោះទេ ពីមុនមក ខ្លួនមិនដែលមានទំនាស់ជាមួយបងស្រីឈ្មោះ [redacted] ថុល និងឈ្មោះ [redacted] ស្រីលាប នោះទេ ប៉ុន្តែខ្លួនធ្លាប់មានទំនាស់ម្ដងនៅមុន

ថ្ងៃកើតហេតុប្រហែលជា ៤ ទៅ ៥ថ្ងៃ ដោយបងឈ្មោះ [redacted] ចុល បានមកចោទប្រកាន់លើខ្លួនថាលួចខ្សែភ្លើងរបស់គេ តែការពិតខ្លួនមិនបានដឹងនោះទេ។ ខ្លួនសំណូមពរដល់តុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ព្រោះរឿងហេតុដែលកើតឡើងខាងលើនេះ ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ព្រោះបងរបស់ខ្លួនឈ្មោះ [redacted] ចុល និងក្មួយឈ្មោះ [redacted] ស្រីលាប ជាអ្នកបង្កឡើង និងបានវាយមកលើខ្លួនមុននោះទេ។ ហើយខ្លួនសូមស្នើសុំដល់តុលាការជួយផ្សះផ្សា និងសម្របសម្រួលឱ្យខ្លួន និងបងស្រីឈ្មោះ [redacted] ចុល ព្រមទាំងក្មួយឈ្មោះ សេង ស្រីលាប ឱ្យត្រូវរ៉ូវ និងបញ្ចប់ទំនាស់ជាមួយគ្នាវិញ ព្រោះខ្លួនមិនចង់មានរឿងវែងឆ្ងាយជាមួយគ្នាបន្តទៀតនោះទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចុល បានឆ្លើយថា: ចំពោះឈ្មោះ [redacted] សម្បត្តិ ត្រូវជាប្អូនបង្កើតរបស់ខ្លួន ដោយផ្ទះរបស់គេនៅជាប់នឹងផ្ទះរបស់ខ្លួន ហើយគេបានប្រកបរបររកស៊ីលក់សាច់ក្លែប និងមានចាក់ធុងបាស បើកខារ៉ាអូខេច្រៀង លុះក្រោយមកនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល ៧ និង៣០នាទីយប់ ដែលជាថ្ងៃកើតហេតុ ឈ្មោះ [redacted] សម្បត្តិ បានបើកខារ៉ាអូខេច្រៀងរហូតដល់ម៉ោង ១០ និង ៣០នាទីយប់ ហើយនៅមិនទាន់បិទនោះទេ ដោយគេនិងបក្ខពួកបាននាំគ្នាច្រៀងបង្ហូសំឡេងយ៉ាងខ្លាំងធ្វើមានសំឡេងរំខានដល់ខ្លួន ព្រោះតែផ្ទះនៅជិតគ្នា ដែលធ្វើឱ្យខ្លួនសម្រាកមិនបាន ដោយនៅពេលនោះខ្លួនបានចេញមកខាងមុខផ្ទះរបស់ខ្លួន ហើយក៏បានប្រាប់ទៅប្អូន [redacted] សម្បត្តិ ថា “អូនហ្នាម៉ោង១០កន្លះហើយ ល្មមបិទ សម្រាកហើយ ឈប់ច្រៀងទៅប៉ុណ្ណឹងបានហើយ ព្រោះយប់ជ្រៅហើយ ហើយខ្លួនមានជំងឺលើសឈាម និងទឹកនោមផ្អែមផង សុំសម្រាក” រួចក៏បានមនុស្សស្រីម្នាក់បានឆ្លើយមកដាក់ខ្លួនថា “កុំចេះ! កន្លែងគេរកស៊ី គេច្រៀងតែពីរទៅបីបទទៀតឈប់ហើយ” ខ្លួនក៏បានតបវិញថា “ច្រៀងយ៉ាងមិចទៀតម៉ោង១០កន្លះហ្នឹង ខ្លួនមានជំងឺផង”។ ខ្លួនក៏បានខលហៅកូនរបស់ខ្លួនឈ្មោះ [redacted] ស្រីលាប ឱ្យមកយកខ្លួនទៅផ្ទះកូនរបស់ខ្លួនដែលរស់នៅជិតនោះដែរ។ បន្តិចក្រោយមក កូនរបស់ខ្លួនឈ្មោះ [redacted] ស្រីលាប ក៏បានមកដល់ ហើយបានទៅសួរមនុស្សស្រីដែលបានជជែកគ្នាជាមួយនឹងខ្លួននោះ រួចឈ្មោះ [redacted] សម្បត្តិ ក៏បានមកដល់ ហើយបានស្រែកថាឱ្យឈ្មោះ [redacted] លាបថាមីលាបៗ រួចហើយឈ្មោះ [redacted] សម្បត្តិ ក៏បានរុញកូនខ្លួនឈ្មោះ [redacted] លាប បណ្តាលឱ្យគេដួលអុកគូថទៅលើផ្លូវចំនួន០២លើក ហើយឈ្មោះ [redacted] សម្បត្តិ ក៏បានកាច់កកូនរបស់ខ្លួន និងបានអូសគេចេញពីផ្ទះរបស់ឈ្មោះ [redacted] សម្បត្តិ រហូតដល់ចិញ្ចើមផ្លូវជាតិម្ខាងទៀត និងបណ្តាលឱ្យមានរបួសរយះកំភួនជើង និងមានដាច់រលាត់ដៃ ពេលខ្លួនចូលទៅឃាត់ ស្រាប់តែឈ្មោះ [redacted] សម្បត្តិ បានស្ទុះមកវាយខ្លួនចំនួន០១ដៃចំ កណ្តាលមុខបណ្តាលឱ្យដួលទៅលើផ្លូវជាតិ និងមានរងរបួសកែងដៃ និងជង្គង់ ហើយកូនរបស់ខ្លួនឈ្មោះ [redacted] ផល្លា បានមកយកខ្លួនទៅមន្ទីរពេទ្យ រីឯកូនឈ្មោះ [redacted] ស្រីលាប មិនបានទៅមន្ទីរពេទ្យជាមួយខ្លួននោះទេ ។ ខ្លួនសូមបញ្ជាក់ផងដែរថាពីមុនមក ខ្លួនមិនដែលមានទំនាស់ជាមួយឈ្មោះ [redacted] សម្បត្តិ នោះទេ ។ ដោយសារតែជាបងប្អូនគ្នាក្នុងរឿងនេះនាងខ្ញុំបានសម្របសម្រួលគ្នារួចហើយ នាងខ្ញុំមិនទាមទារសំណងនោះទេ ។

-ជនរងគ្រោះឈ្មោះ [redacted] ស្រីលាប បានឆ្លើយថា ចំពោះហេតុការណ៍ដែលបានកើតឡើងខាងលើនេះ គឺខ្លួនសូមឆ្លើយបំភ្លឺជូនតុលាការថា នៅថ្ងៃកើតហេតុត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ ឈ្មោះ [redacted] សម្បត្តិ បានចាក់បាស និងច្រៀងខារ៉ាអូខេ ដោយផ្ទះរបស់គាត់បានបើករកស៊ីលក់សាច់ក្លែម នៅថ្ងៃកើតហេតុនេះដែរ វេលាម៉ោងប្រហែល ១០ និង៣០នាទីយប់ ម្តាយរបស់ខ្លួនឈ្មោះ [redacted] ចុល បានខលហៅខ្លួនឱ្យទៅយកគាត់ទៅលេងផ្ទះប្អូនឈ្មោះ [redacted] ផល្លា ដើម្បីទៅសម្រាកនៅទីនោះដោយសារតែផ្ទះរបស់គាត់មិនអាចសម្រាកបាន ព្រោះផ្ទះរបស់ពូឈ្មោះ [redacted] សម្បត្តិ ដែលនៅជិតនោះ បានចាក់បាសច្រៀងការ៉ាអូខេរំខានសម្រាកមិនបាន។ រួចហើយខ្លួនក៏បានឱ្យក្មួយឈ្មោះ ម៉ៅ ជូនខ្លួនទៅយកម្តាយឈ្មោះ [redacted] ចុល មកផ្ទះប្អូនឈ្មោះ [redacted] ផល្លា ពេលខ្លួនមកដល់ ស្រាប់តែលឺមនុស្សស្រីម្នាក់និយាយថា “គ្រាន់តែច្រៀងប៉ុណ្ណឹងមិនបានទើសទាល់ម្លេះ! ហើយខ្លួនក៏បានតបវិញថា “ម្តាយខ្ញុំឈឺគាត់ត្រូវការសម្រាក” ហើយស្រាប់តែពេលនោះមានឈ្មោះ [redacted] សម្បត្តិ បាន



Scanned with CamScanner

ស្មុះមករុញខ្លួនបណ្តាលឱ្យដួលផ្ងារក្រោយមួយទំហឹងនៅលើផ្លូវជាតិ ហើយថែមទាំងបាននិយាយឱ្យខ្លួនថា "ដែងកុំ! បន្ទាប់មកខ្លួនក៏បាននិយាយថា "ហេតុអ្វីបានជាមករុញខ្ញុំអញ្ចឹង! ខ្ញុំមិនបានធ្វើអ្វីនោះទេ" រួចឈ្មោះ [redacted] សម្បត្តិ ក៏បានមកចាប់បោចសក់ និងអូសក្បាលខ្លួនមួយទំហឹងទៅលើផ្លូវជាតិម្តងទៀត បណ្តាលឱ្យខ្លួនដាច់រលាត់ ដៃជើងហើយហូរឈាមយ៉ាងខ្លាំង រួចហើយម្តាយខ្លួនក៏បានចូលទៅឃាត់ឈ្មោះ [redacted] សម្បត្តិ កុំឱ្យវាយខ្លួនបន្តទៀតស្រាប់តែឈ្មោះ [redacted] សម្បត្តិ បានបន្តវាយម្តាយខ្លួនឈ្មោះ [redacted] ថុល ទៀត ត្រូវ១ដៃ ចំកណ្តាលសៀតផ្កាបណ្តាលឱ្យម្តាយខ្លួនរងរបួសដាច់ជង្គង់ និងកែងដៃ ។ ខ្លួនសូមបញ្ជាក់ថា កន្លងមកឈ្មោះ [redacted] សម្បត្តិ បានមកសុំម្តាយខ្លួនបើកខារ៉ាអូខេដល់ម៉ោង១១យប់ តែម្តាយខ្លួនមិនព្រមព្រោះឪពុកនិងម្តាយខ្លួនមានជំងឺប្រចាំកាយ ខ្លាចសម្រាននមិនបាន ទើបនៅថ្ងៃកើតហេតុម្តាយរបស់ខ្លួនបានទៅប្រាប់ឈ្មោះ [redacted] សម្បត្តិ កុំឱ្យបើកខារ៉ាអូខេដល់យប់ជ្រៅពេក រួចក៏មានទំនាស់ជាមួយគ្នាតែម្តង។

-សាក្សីឈ្មោះ [redacted] ផល្លា បានឆ្លើយថា នៅថ្ងៃកើតហេតុនេះវេលាម៉ោងប្រហែល ១០ និង ៣០នាទីយប់ ម្តាយរបស់ខ្លួនឈ្មោះ [redacted] ថុល បានខលមកប្រាប់បងស្រីរបស់ខ្លួនឈ្មោះ [redacted] ស្រីលាប ថាឱ្យមកយកគាត់មកផ្ទះខ្លួន ដើម្បីសម្រាក ដោយហេតុថានៅផ្ទះរបស់គាត់មិនអាចសម្រាកបាន ព្រោះផ្ទះរបស់ពូឈ្មោះ [redacted] សម្បត្តិ ចាក់បាសច្រៀង ខារ៉ាអូខេរំខាន មិនអាចសម្រាកបាន។ នៅពេលដែលម្តាយរបស់ខ្លួនខលទៅប្រាប់បងស្រីឈ្មោះ [redacted] ស្រីលាប កូនរបស់ខ្លួនឈ្មោះ ផានិត ហៅ ម៉ៅ ក៏បានទៅឌុបបងស្រីរបស់ខ្លួនឈ្មោះ [redacted] ស្រីលាប ដើម្បីមកយកម្តាយឈ្មោះ [redacted] ថុល ដើម្បីមកផ្ទះរបស់ខ្លួន។ ក្រោយមកកូនរបស់ខ្លួនឈ្មោះ [redacted] និត ហៅ ម៉ៅ បានប្រាប់ខ្លួនថាម៉ាក តាសម្បត្តិ បានវាយយាយ [redacted] ស្រីលាប ពេលនោះខ្លួនក៏បានជិះម៉ូតូមកជាមួយកូនដើម្បីមកផ្ទះម្តាយ។ ពេលមកដល់ក៏ស្រាប់តែឃើញឈ្មោះ [redacted] សម្បត្តិ កំពុងលើកដៃវាយម្តាយខ្លួនហើមកូនដៃ ក្បាល និងរយះជង្គង់។ ចំណែកឯបងស្រីឈ្មោះ [redacted] ស្រីលាប រយះកំភួនជើងហូតឈាមយ៉ាងខ្លាំង។ ពេលនោះខ្លួនក៏បានចូលទៅឃាត់ដែរ ប៉ុន្តែឈ្មោះ [redacted] សម្បត្តិ នៅតែមានការប្រតាយប្រតបគ្នា ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ**

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីរួចមក តំណាងអយ្យការ យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពិតជាប្រើហិង្សាដោយចេតនាទៅលើជនរងគ្រោះឈ្មោះ [redacted] ថុល កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ ប្រព្រឹត្តនៅចំណុចភូមិចុងថ្នល់ សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ ពិតប្រាកដមែន ដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ០៩២ ដ.ស.ព/២៣ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ ដដែល សូមតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

**សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

លោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានដូចតទៅៈ ក្រោយពីបានពិភាក្សាដេញដោលឃើញថាកូនក្តីនិងជនរងគ្រោះគឺជាបងប្អូនបង្កើតនឹងគ្នា ម្យ៉ាងវិញទៀតក្នុងរឿងនេះកើតឡើងដោយសារតែយល់ច្រឡំនោះទេ ហើយពួកគាត់បានសម្របសម្រួលគ្នាដើម្បីបញ្ចប់រឿងរួចហើយដែរ ហេតុនេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្ញុំបាទស្នើសុំឱ្យតុលាការមេត្តាព្យួរទោសដល់កូនក្តីខ្លួនផង ។

**សម្តីចុងក្រោយរបស់ជនជាប់ចោទ**

ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានសំណូមពរដល់តុលាការមេត្តាលើកលែងការចោទប្រកាន់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ



Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ

**<u>សំអាងហេតុ</u>**

១-តាមដីកាដំណោះស្រាយលេខ ៨៩/២០២៣ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ បានបញ្ជូនជនត្រូវចោទឈ្មោះ [redacted]សម្បត្តិ ភេទប្រុស អាយុ ៦១ឆ្នាំ មកតុលាការជំនុំជម្រះពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចភូមិចុងថ្នល់ សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ បទល្មើសព្រហ្មទណ្ឌមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២.តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងទាំងអស់ដែលស្វែងរកដោយចៅក្រមស៊ើបសួរពុំមានភាពផ្ទុយគ្នាទេ ។ យោងតាមមាត្រា ១១០ និងមាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាចឱ្យតុលាការជឿបានថា កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ នៅចំណុចភូមិចុងថ្នល់ សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ ពិតជាមានករណី ហិង្សាដោយចេតនា ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ ៦១ឆ្នាំ ប្រាកដមែន។

៣.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]សម្បត្តិ បានឆ្លើយថា នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ ខ្លួនពុំបានប្រើប្រាស់អំពើហិង្សាទៅលើជនរងគ្រោះឈ្មោះ [redacted] ថុល និងឈ្មោះ [redacted]ស្រីលាប នោះទេ ដែលចម្លើយបដិសេធនេះគ្រាន់តែជាការឆ្លើយដោះសារដើម្បីឱ្យរួចផុតពីបទចោទប្រកាន់ប៉ុណ្ណោះ ជនជាប់ចោទពុំមានភស្តុតាងណាមួយដាក់បញ្ជាក់ជូនតុលាការដើម្បីធ្វើការដោះបន្ទុកសម្រាប់ខ្លួននោះឡើយ ហេតុនេះមិនអាចឱ្យតុលាការជឿបានឡើយ ផ្ទុយទៅវិញផ្អែកតាមចម្លើយរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងរូបថតព្រមទាំងចម្លើយរបស់សាក្សីដែលនៅក្នុងហេតុការណ៍ សបញ្ជាក់ឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពិតជាបានប្រើប្រាស់អំពើហិង្សាលើជនរងគ្រោះពិតមែន ។

៤.តាមចម្លើយរបស់ជនរងគ្រោះ ចម្លើយសាក្សី និងរបាយការណ៍មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពិតជាធ្វើសកម្មភាពប្រព្រឹត្តហិង្សាដោយចេតនា ទៅលើជនរងគ្រោះ ប្រាកដមែន។ ភស្តុតាងទាំងនេះតុលាការអាចពិចារណាបានតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ដែលបានប្រើហិង្សាវាយទៅលើជនរងគ្រោះបណ្តាលឱ្យរងរបួស បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គម ដែលមាត្រា ២ និងមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ បានហាមជាដាច់ខាតនឹងត្រូវផ្តន្ទាទោស។ សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការប្រព្រឹត្តអំពើហិង្សាដោយចេតនាបណ្តាលឱ្យរងរបួសដល់ជនរងគ្រោះ ប្រាកដមែន។ ហេតុនេះមានធាតុផ្សំគ្រប់គ្រាន់ពីបទ **ហិង្សាដោយចេតនា** តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

៦.ជនជាប់ចោទ ជាសមត្ថជនដែលមានសមត្ថភាពអាចទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌបាន ពោលគឺពុំមានភស្តុតាងណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។ គប្បីតុលាការពិចារណាលើមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ។

៧.ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានឆ្លើយនៅចំពោះមុខតុលាការ និងសហការជាមួយតុលាការ មួយវិញទៀតជនជាប់ចោទទើបតែប្រព្រឹត្តកំហុសដែលល្មើសនឹងច្បាប់លើកដំបូង ហើយបទល្មើសនេះក៏បង្កព្យសនកម្មតិចតួចម្យ៉ាងទៀតជនជាប់ចោទពុំធ្លាប់មានប្រវត្តិផ្តន្ទាទោសដោយតុលាការពីមុននោះទេ។ ហេតុនេះគប្បីតុលាកាពិចារណាក្នុងការព្យួរទោសដល់ជនជាប់ចោទតាមមាត្រា ១០៧ និង មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៨-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ក្រោយពីបានធ្វើការសាកសួរពិភាក្សាដេញដោលយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពិតជាប្រើហិង្សាដោយចេតនាទៅលើជនរងគ្រោះឈ្មោះ [redacted] ថុល កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ ប្រព្រឹត្តនៅចំណុចភូមិចុងថ្នល់ សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ ពិតប្រាកដមែន ។ ដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ០៩២ ដ.ស.ព ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ ដដែល សូមតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់។ សេចក្តីសន្និដ្ឋាននេះមានមូលដ្ឋានគ្រប់គ្រាន់អាចឱ្យតុលាការពិចារណាបាន ។

៩-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានពិភាក្សាដេញដោលឃើញថាកូនក្តីខ្លួនពុំបានវាយលើជនរងគ្រោះនោះទេ ម្យ៉ាងវិញទៀតក្នុងរឿងនេះកើតឡើងដោយសារតែយល់ច្រឡំ ហើយកូនក្តីខ្លួន និងជនរងគ្រោះគឺជាបងប្អូនបង្កើតនឹងគ្នា ហើយពួកគាត់បានសម្របសម្រួលគ្នាដើម្បីបញ្ចប់រឿងរួចហើយដែរ ហេតុនេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្ញុំបាទស្នើសុំឱ្យតុលាការមេត្តាឱ្យកូនក្តីខ្ញុំបាទរួចផុតពីបទចោទប្រកាន់ ។ គប្បីតុលាការពិនិត្យ ពិចារណាសម្រេចតាមច្បាប់។

១០.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថុល ពុំប្តឹងទាមទារសំណងរដ្ឋប្បវេណីនោះទេ ដោយហេតុថាខ្លួនជាបងប្អូនបង្កើតនឹងគ្នា ម្យ៉ាងវិញទៀតខ្លួនក៏បានសម្របសម្រួលគ្នារួចហើយដែរ ដោយមិនចាប់ទោសអ្វូសដំណើរគ្នាទៀតទេ ។ ហេតុនេះ គប្បីតុលាការមិនពិចារណាអំពីសំណងឡើយ ។

១១.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ ៦១ឆ្នាំ ជាតិខ្មែរ ពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចភូមិចុងថ្នល់ សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ។

**<u>ហេតុដូច្នេះសម្រេច</u>**

-ផ្តន្ទាទោសលើឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ ៦១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល **១ (មួយ) ឆ្នាំ** តែទោសនេះត្រូវព្យួរទាំងស្រុង តាមមាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

ពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចភូមិចុងថ្នល់ សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថុល ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| --- | --- |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១៥រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

តាកែវ, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០២៣

| បានឃើញ<br>**ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជីសវនាការ** |
| --- | --- |
| [redacted] | [redacted] |



Scanned with CamScanner